គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ៖ ៤១៣/១៩ ស.ជ.ក

# របាយការណ៍ខែសីហា
# ស្តីពី
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងទិសដៅខែកញ្ញា ឆ្នាំ២០១៩

## I. ស្ថានភាពទូទៅ

ស្ថានភាពបទល្មើសជួញដូរមនុស្ស ត្រូវបានបង្ការ ទប់ស្កាត់ និងបង្ក្រាប ជាបន្តបន្ទាប់ ដោយមានការខិតខំប្រឹងប្រែងគ្រប់បែបយ៉ាង និងមានការសហការគ្នាបានល្អ រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រសួង ស្ថាប័ន ជាសមាជិក គ.ជ.ប.ជ និងអង្គភាពពាក់ព័ន្ធនានា រួមទាំងលេខាធិការដ្ឋាន គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ)។ ក្រោយពីរាជរដ្ឋាភិបាលថៃ បានផ្តល់ភាពស្របច្បាប់ដល់ពលករប្រមាណ ជាងមួយលានប្រាំមួយម៉ឺននាក់ ហើយក៏ដោយ ក៏ការធ្វើចំណាកស្រុកឆ្លងដែន ឬទេសន្តប្រវេសន៍មិនប្រក្រតីក៏នៅតែមានដដែល ពលរដ្ឋខ្មែរនៅតែបាន និងកំពុងចូលទៅធ្វើការនៅប្រទេសថៃដោយខុសច្បាប់ជាបន្តទៅទៀត ទោះបីត្រូវជួបប្រទះបញ្ហាប្រឈម ហានីភ័យនានា ដូចជា ការបញ្ជូនត្រឡប់មកវិញ ការឃាត់ខ្លួន ការដាក់ទោសទណ្ឌ ពីអាជ្ញាធរប្រទេសថៃ រងការកេងប្រវ័ញ្ច ខាតបង់ប្រាក់កាស និងពេលវេលា ជាដើម។ល។ ប្រជាពលរដ្ឋមួយចំនួន នៅតែចាញ់ឧបាយកលមេខ្យល់បោកប្រាស់ ដែលប្រើរូបភាពជាភ្នាក់ងារមានសមត្ថកិច្ច ផ្តល់ឯកសារក្លែងក្លាយជាអ្នករត់ការផ្តល់ភាពស្របច្បាប់ ហើយទាមទារកម្រៃខ្ពស់ពីពលករ ឬជាអ្នកជ្រើសរើស បណ្តុះបណ្តាល និងបញ្ជូនទៅរកការងារក្រៅប្រទេស មានប្រាក់ខែច្រើន។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកើតមានខាងលើនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការ បានបង្កើនការយកចិត្តទុកដាក់ សម្របសម្រួល ពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ជាសមាជិក និងជំរុញសកម្មភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី-ខេត្ត មន្ទីរ អង្គភាព ដៃគូជាតិ និងអន្តរជាតិ ក៏ដូចជាសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាព និងកិច្ចប្រតិបត្តិការដើម្បីដោះស្រាយបញ្ហារួមគ្នា ដោយទទួលបានលទ្ធផល ដូចខាងក្រោម៖

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការងារ ច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការអនុវត្តច្បាប់ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ

ក.១. ការកសាងច្បាប់

- ក្រសួងយុត្តិធម៌ និងក្រសួងកិច្ចការនារី បានដឹកនាំធ្វើសេចក្តីព្រាងច្បាប់ ស្តីពី"ការពពោះជំនួស"។
- ក្រសួងយុត្តិធម៌ បានរៀបចំសេចក្តីព្រាងច្បាប់៖
  - ស្តីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ" (MLA)
  - ស្តីពី "ការប្រឆាំងអំពើរត់ពន្ធមនុស្ស"។

ក.២. សន្ធិសញ្ញា

- ក្រសួងយុត្តិធម៌

-បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសឡាវ បារាំង និងប្រទេសកូរ៉េខាងត្បូង ស្តីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ"

-បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសអង់គ្លេស ប៉េរូ និងប្រទេសឡាវ ស្តីពី "ការបញ្ជូនទណ្ឌិត"។

ក.៣. គោលនយោបាយ និងអនុស្សរណៈនៃការយោគយល់គ្នា

- ក្រសួងអប់រំ យុវជន និងកីឡា៖ កំពុងធ្វើសេចក្តីព្រាងគោលនយោបាយ ស្តីពី "កិច្ចការការពារកុមារតាមសាលារៀន"។
- ក្រសួងទេសចរណ៍ ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការអនុវត្តគម្រោងកុមារភាពជាមួយអង្គការ Friends International។
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានប្រជុំថ្នាក់មន្ត្រីបច្ចេកទេសលើកទី៤ និងថ្នាក់រដ្ឋមន្ត្រីលើកទី២ ដើម្បីអនុវត្តអនុស្សរណៈនៃការយោគយល់គ្នារវាង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃប្រទេសម៉ាឡេស៊ី ស្តីពី "ការជ្រើសរើស ការបញ្ជូន និងការគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ី"។

ក.៤. លិខិតបទដ្ឋានគតិយុត្ត

- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖ ធ្វើសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត "សម្រាប់អនុវត្តលក្ខខណ្ឌការងារកម្មករការងារផ្ទះ"។
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖ ធ្វើសេចក្តីព្រាងរៀបចំអនុក្រឹត្យ ស្តីពីរបបគោលនយោបាយសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចគ្រប់ទម្រង់ផ្សេងៗទៀត ដែលស្នាក់នៅមណ្ឌលសំចតរបស់រដ្ឋ និងរស់នៅតាមសហគមន៍។

## ខ. ការបង្ការ ទប់ស្កាត់

### ខ.១. តាមរយៈការលើកកម្ពស់ការយល់ដឹង

#### ខ.១.១. ការផ្សព្វផ្សាយតាមរយៈទិវាអន្តរសាសនា

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានសហការជាមួយក្រសួងធម្មការ និងសាសនា និងអង្គការការីតាសកម្ពុជា រៀបចំ "វេទិកាជាតិ អន្តរសាសនា លើកទី៣ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងទាសភាពសម័យទំនើប" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ**។ កម្មវិធីនេះត្រូវបានធ្វើឡើងនៅមជ្ឈមណ្ឌលតាំងពិពណ៌ និងសាលមហោស្រពកោះពេជ្រ ដោយមានការយាងនិមន្ត និងអញ្ជើញចូលរួមពីសំណាក់ថ្នាក់ដឹកនាំ មន្ត្រីរាជការ កងកម្លាំង ព្រះសង្ឃ បព្វជិត-សាសនិកជនសាសនាផ្សេងៗ លោកគ្រូ អ្នកគ្រូ សិស្ស និស្សិត និងប្រជាពលរដ្ឋ សរុបចំនួន ១.៤១០អង្គ/នាក់។

#### ខ.១.២. ការផ្សព្វផ្សាយដោយផ្ទាល់តាមរយៈកិច្ចប្រជុំ និងវេទិកាសាធារណៈ

នៅក្នុងខែសីហា ឆ្នាំ២០១៩នេះ ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ មន្ទីរពាក់ព័ន្ធ បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ ការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ មានសុវត្ថិភាព" និង

កម្មវិធីផ្សេងៗ ដល់មន្ត្រីរាជការ សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ សាសនិកជន និងប្រជាពលរដ្ឋ សរុបចំនួន ៧.២១៤លើក មានអ្នកចូលរួមសរុបចំនួន ៤០៦.៣៩៦នាក់ (ធៀបនឹងខែកក្កដា មានចំនួន ៤០០.៧៣២នាក់ គឺមានការកើនឡើងចំនួន ៥.៦៧៣នាក់ ស្មើនឹង១,៤១% ក្នុងនោះស្ត្រីចំនួន ២០៧.០២៣នាក់ ដូចមានតារាងលម្អិតខាងក្រោម៖

តារាងទិន្នន័យការអប់រំផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ និងវេទិកាសាធារណៈ

| ល.រ | ក្រសួង ស្ថាប័ន | ផ្សព្វផ្សាយ | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | រាជធានី-ខេត្ត | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
| ក្រសួង ស្ថាប័ន | | | | | | | |
| ១ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ១៩៨ | ១៥.០០៦ | ៨.៣២៩ | | | |
| | សរុប ក្រសួង ស្ថាប័ន | ១៩៨ លើក | ១៥.០០៦ នាក់ | ៨.៣២៩ នាក់ | | | |
| | | | | | | | |
| ១ | រាជធានីភ្នំពេញ | | | | | | |
| ២ | ខេត្តកណ្តាល | ៣០៦ | ១០.៦៤០ | ៥.២៤០ | ៩៣៤ | ៥៥.៧០៩ | ២៥.៣៨៣ |
| ៣ | ខេត្តបាត់ដំបង | ៩២១ | ៥៤.៣៨៤ | ២៧.៣២៩ | ៥៧៣ | ២៣.៧៨៩ | ១១.៨៩៦ |
| ៤ | ខេត្តពោធិ៍សាត់ | ៤៥៧ | ៣១.១៧៩ | ១៧.០៨២ | ១២២ | ៥.០៥៦ | ២.៣៨២ |
| ៥ | ខេត្តសៀមរាប | ៥១២ | ៣៤.២៧៣ | ២០.៧១៣ | ៤៤ | ១.៩២៤ | ១.៤១៩ |
| ៦ | ខេត្តកំពង់ឆ្នាំង | ១.៤១៦ | ៨៤.៤៦០ | ៤១៩៧៧ | ៦២៦ | ២៧.៤១៥ | ១៤.៨៥៣ |
| ៧ | ខេត្តកំពង់ចាម | | | | | | |
| ៨ | ខេត្តព្រះសីហនុ | ២២ | ៣៤៧ | ១៦៩ | ១៦ | ៨៦២ | ២៤៧ |
| ៩ | ខេត្តព្រះវិហារ | | | | | | |
| ១០ | ខេត្តស្វាយរៀង | ២០ | ៥៣៥ | ៣៩៧ | ៣១៩ | ១២.៧១៧ | ៦.៧០៤ |
| ១១ | ខេត្តប៉ៃលិន | ៤៣ | ៥.០៦៨ | ២.៦១៤ | ៣៤ | ១.៦៧១ | ១.១០៤ |
| ១២ | ខេត្តកោះកុង | ៦ | ១០៦ | ៩៥ | ៥៣ | ៣.៤៧១ | ១.៨០៤ |
| ១៣ | ខេត្តកំពត | | | | | | |
| ១៤ | ខេត្តកំពង់ធំ | | | | | | |
| ១៥ | ខេត្តតាកែវ | ២៧៤ | ១៥.៦៥៦ | ៦.៥៧៥ | ១៥៦ | ៥.៩៩៨ | ២.៤២២ |
| ១៦ | ខេត្តក្រចេះ | ៨ | ៤០៨ | ២៤៣ | | | |
| ១៧ | ខេត្តកែប | ១៣ | ៣.២១៦ | ១.៤៧៤ | | | |
| ១៨ | ខេត្តកំពង់ស្ពឺ | ២៣ | ៤.១២០ | ២.០៤៣ | | | |
| ១៩ | ខេត្តស្ទឹងត្រែង | | | | | | |
| ២០ | ខេត្តរតនគិរី | ៣៦ | ១.៧១០ | ៩២១ | ៦៨ | ៥.៤៨៧ | ៣.២៦៩ |
| ២១ | ខេត្តព្រៃវែង | | | | ៨ | ៣៦៦ | ០ |
| ២២ | ខេត្តត្បូងឃ្មុំ | | | | ១ | ៤៣ | ៣៩ |
| ២៣ | ខេត្តបន្ទាយមានជ័យ | | | | | | |
| ២៤ | ខេត្តឧត្តរមានជ័យ | | | | ៥ | ៧៨០ | ៣០០ |
| ២៥ | ខេត្តមណ្ឌលគិរី | | | | | | |
| | សរុប រាជធានី-ខេត្ត | ៤.០៥៧ លើក | ២៤៦.១០២ នាក់ | ១២៦.៨៧២ នាក់ | ២.៩៥៩ លើក | ១៤៥.២៨៨ នាក់ | ៧១.៨២២ នាក់ |
| សរុបរួម ក្រសួង ស្ថាប័ន និងរាជធានី-ខេត្ត | | ចំនួន ៧.២១៤ លើក | អ្នកចូលរួមសរុបចំនួន ៤០៦.៣៩៦ នាក់ | | ស្ត្រីចំនួន ២០៧.០២៣ នាក់ | | |

### ខ.១.៣. ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និង ប្រព័ន្ធអេឡិកត្រូនិក

- ខេត្តសៀមរាបៈ

មន្ទីរព័ត៌មានខេត្ត បានសហការជាមួយអង្គភាព អាជ្ញាធរ និងអង្គការពាក់ព័ន្ធ ធ្វើកម្មវិធី "យើងធ្វើបាន" និង "សន្ទនាមតិ" បានសរុបចំនួន ២៨លើក (ផ្សាយផ្ទាល់ ០៨លើក ចាក់ផ្សាយឡើងវិញ ២០លើក) ។

- ខេត្តតាកែវៈ

ផ្សព្វផ្សាយព័ត៌មាន និងច្បាប់ពាក់ព័ន្ធការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមរយៈវិទ្យុ បានចំនួន ០៣អត្ថបទ និង ៣៨លើក។

## ខ.២. ការបង្ការ ទប់ស្កាត់ តាមវិធានការជំនាញ

### ខ.២.១. វិធានការជំនាញអន្តោប្រវេសន៍៖ ការគ្រប់គ្រងជនបរទេស

១. ការងារអនុវត្តនីតិវិធី និងការបណ្តេញចេញជនបរទេសខុសច្បាប់: ជនបរទេសដែលល្មើសច្បាប់ស្តីពីអន្តោប្រវេសន៍ ត្រូវបានបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជា សរុបចំនួន ៤៨លើក មនុស្សចំនួន ១០០នាក់(ស្រី ១១នាក់) មាន ១៨សញ្ជាតិ។

២. ការបដិសេធមិនឲ្យចូលប្រទេស: ការពង្រឹង បង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើស លើជនបរទេសចូល-ចេញតាមបណ្តាច្រកទ្វារព្រំដែនអន្តរជាតិនានា ក្នុងខែនេះបានធ្វើការបដិសេធមិនឲ្យចូលប្រទេសមានចំនួន ៧៤លើក មនុស្សចំនួន ១៣៩នាក់ លើ ២១៨នាក់ (ថយ ៣៦,២៣%) ក្នុងនោះមាន៖

- គោលបំណងនៃការធ្វើដំណើរមិនច្បាស់លាស់ គ្មានប្រាក់គ្រប់គ្រាន់ក្នុងការស្នាក់នៅព្រះរាជាណាកចក្រកម្ពុជាចំនួន ៦៧លើក មនុស្សចំនួន ១៣២នាក់ មាន ២៤សញ្ជាតិ។
- បទល្មើសផ្សេងៗចំនួន ០៧លើក មនុស្សចំនួន ០៧នាក់ មាន ០៧សញ្ជាតិ។

### ខ.២.២. ការគ្រប់គ្រងស្ថិតិ៖ បច្ចុប្បន្នភាពចំណាកស្រុក

▪ **អគ្គស្នងការដ្ឋាននគរបាលជាតិ**

ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានធ្វើបច្ចុប្បន្នភាពទិន្នន័យប្រចាំខែ ចំពោះពលករចំណាកស្រុកទៅក្រៅប្រទេស សរុបចំនួន ៣៦១.៧១៥នាក់/២៩៩.៥៣៨នាក់ (ស្រី ១៤៣.២៤២នាក់) អនីតិជន ៦.៨៧០នាក់ (ស្រី ២.៧០២នាក់) ក្នុងនោះស្របច្បាប់ចំនួន ២២១.៩១៩នាក់/១៩០.៩៤៤នាក់(ស្រី ៨១.៤៥៧នាក់) អនីតិជន ៦៥៨នាក់ (ស្រី ២៧៨នាក់) មិនស្របច្បាប់ចំនួន ១៣៩.៧៩៦នាក់/១០៨.៥៩៤នាក់(ស្រី ៦១.៧៨៥នាក់) អនីតិជន ៦.២១២នាក់ (ស្រី ២.៤២៤នាក់) បើប្រៀបធៀបនឹងខែកក្កដា គឺមានការកើនឡើងចំនួន ៦២.១៧៧នាក់ ស្មើនឹង ២០,៧៥%។

- **ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង៖** កម្លាំងល្បាតតាមខ្សែបន្ទាត់ព្រំដែន របស់វរៈសេនាតូចការពារព្រំដែនគោកលេខ ៨១៧ ៨១៩ ៨២៣ និង ៣១០ បានចេញល្បាតតាមបន្ទាត់ព្រំដែនដើម្បីទប់ស្កាត់ការលួចឆ្លងដែនខុសច្បាប់ ចំនួន ៦៤លើក ពុំប្រទះឃើញពលករឆ្លងដែនខុសច្បាប់ទេ។
- **ស្នងការដ្ឋាននគរបាលខេត្តរតនគិរី៖** កម្លាំងល្បាតតាមខ្សែបន្ទាត់ព្រំដែន របស់វរៈនគរបាលការពារព្រំដែនគោក បានចេញល្បាតតាមបន្ទាត់ព្រំដែនភូមិសាស្ត្ររបស់ខ្លួន ចំនួន ៧០លើក (ព្រំដែនកម្ពុជា-វៀតណាម ៦៤លើក និងព្រំដែនកម្ពុជា-ឡាវ ០៦លើក)ដើម្បីទប់ស្កាត់បទល្មើសឆ្លងដែនខុសច្បាប់។

២.២.៣. វិធានការបង្ការ ទប់ស្កាត់ តាមជំនាញគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ

- អគ្គស្នងការដ្ឋាននគរបាលជាតិ
  - ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានធ្វើបច្ចុប្បន្នភាពទិន្នន័យគោលដៅសង្ស័យប្រព្រឹត្តបទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ សរុបចំនួន ៧៥គោលដៅ ក្នុងនោះអំពើជួញដូរមនុស្សចំនួន ០៩គោលដៅ និងអំពើធ្វើអាជីវកម្មផ្លូវភេទចំនួន ៦៦គោលដៅ។
  - ស្នងការដ្ឋាននគរបាលខេត្តតាកែវ មណ្ឌលគិរី កែប ស្ទឹងត្រែង ស្វាយរៀង ក្រចេះ ឧត្តរមានជ័យ និងខេត្តកោះកុង បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ចារកម្ម និងផ្សព្វផ្សាយ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្មស្ត្រីក្នុងហាងម៉ាស្សា ខារ៉ាអូខេ បានចំនួន ៥៥២គោលដៅ មានមនុស្សចំនួន ២.៣២៧នាក់ (ស្រី ១.៧៤៦នាក់)។
  - ស្នងការដ្ឋាននគរបាលខេត្តស្វាយរៀង កំពង់ស្ពឺ តាកែវ ស្ទឹងត្រែង ព្រៃវែង ក្រចេះ និងខេត្តព្រះវិហារ ល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ បានចំនួន ៣៩លើក។

**២.២.៤. ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស**

- ក្រសួងមហាផ្ទៃ

  នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តច្បាប់) នៃច្រកចេញចូលតែមួយ របស់ក្រសួងមហាផ្ទៃទទួលបន្ទុកការងារអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស បានធ្វើការសម្ភាសពលរដ្ឋខ្មែរ និងជនបរទេស សរុបចំនួន ១៥២គូ ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។ បានទំនាក់ទំនងទៅនារីខ្មែរ ដែលទៅរស់នៅជាមួយស្វាមីនៅក្រៅប្រទេស តាមរយៈទូរស័ព្ទផ្ទាល់ ចំនួន ១៩នាក់ ដើម្បីតាមដានស្ថានភាព ដែលសង្ស័យថាអាចកើតមានការជួញដូរមនុស្ស តាមរយៈការរៀបអាពាហ៍ពិពាហ៍។

## ២.៣. កិច្ចការពារកុមារ ពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ

- **ខេត្តកំពង់ឆ្នាំង៖**

  ស្នងការដ្ឋាននគរបាលខេត្ត បានចុះត្រួតពិនិត្យសិប្បកម្មឡឥដ្ឋចំនួន ០៥កន្លែង មានកម្មករសរុប ១២០នាក់ (ស្រី ៥៩នាក់) ដោយពិនិត្យឃើញថា ពុំមានកម្មករជាអនីតិជនទេ។

- **ខេត្តប៉ៃលិន៖**

  បានចុះធ្វើអធិការកិច្ច ដើម្បីទប់ស្កាត់ និងលុបបំបាត់នូវទម្រង់ជួញដូរធ្ងន់ធ្ងរលើពលកម្មកុមារ នៅតាមសហគ្រាស គ្រឹះស្ថាន ដែលមានប្រើប្រាស់កម្លាំងពលកម្មដូចជា សែឡូ កាស៊ីណូ ឡឥដ្ឋ ភោជនីយដ្ឋាន ចំនួន ៨០កន្លែង។

- **ខេត្តព្រះសីហនុ៖**

  ស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ សហការជាមួយអង្គការម្លប់តាប៉ាង ដើម្បីការពារសុវត្ថិភាពកុមារ បានដាក់បណ្តាញម៉ូតូឌុប និងក្រុមម៉ូតូកង់បី ផ្ទះសំណាក់ សណ្ឋាគារ អ្នកលក់តាមឆ្នេរសមុទ្រ បណ្តាញតាមសហគមន៍ និងផ្នែកភ្នាក់ងារទេសចរណ៍ សរុបចំនួន ១.១៣៣នាក់។

- **ខេត្តរតនគិរី៖**

  មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចុះធ្វើអធិការកិច្ចសាមញ្ញសរុបចំនួន ០២លើក និងចុះធ្វើអធិការកិច្ចពិសេសចំនួន ០៣លើក ក្នុងគោលបំណងពិនិត្យលើការងារអនុវត្តច្បាប់ ស្តីពីការងារ និងការបង្ការការប្រើប្រាស់កម្លាំងពលកម្មខុសច្បាប់ ការប្រើប្រាស់ពលកម្មកុមារ។

- ខេត្តក្រចេះ៖

មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត បានចុះត្រួតពិនិត្យមណ្ឌល អង្គការ ដំណឹងល្អចំនួន ០៤ ។

### ខ.៤. ការកាត់បន្ថយភាពងាយរងគ្រោះ តាមរយៈការផ្តល់ប័ណ្ណព្រំដែនដល់មុខសញ្ញាងាយរងគ្រោះ

- រដ្ឋបាលខេត្តចំនួន០៣ គឺខេត្តបាត់ដំបង បន្ទាយមានជ័យ និងខេត្តប៉ៃលិន ដែលមានច្រកប៉ុស្តិ៍អន្តរជាតិនៅតាមព្រំដែន បានផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ (Border Pass) សរុបចំនួន ៧.៤៨០ប័ណ្ណ ដល់ពលរដ្ឋខ្មែរដែលរស់នៅក្នុងខេត្តជាប់ព្រំដែន មាន:
  - ខេត្តបាត់ដំបង ចំនួន ៤.៨៨៧ប័ណ្ណ
  - ខេត្តបន្ទាយមានជ័យ ចំនួន ២.០៦៤ប័ណ្ណ
  - ខេត្តប៉ៃលិន ចំនួន ៥២៩ប័ណ្ណ។

## គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### គ.១. ការងារអនុវត្តច្បាប់

លទ្ធផលបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខាងក្រោមនេះទទួលបានពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត៖ រាជធានីភ្នំពេញ ខេត្តសៀមរាប ព្រះសីហនុ និងខេត្តរតនគិរី។

#### គ.១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

អគ្គស្នងការដ្ឋាននគរបាលជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន ០៩ករណី (ធៀបនឹងខែកក្កដា មានចំនួន ១៧ករណី ថយចុះ ០៨ករណី) ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន ១២នាក់(ស្រី ០៦នាក់ ជនបរទេស ០១នាក់ សញ្ជាតិអាមេរិក។

សង្គ្រោះជនរងគ្រោះ ចំនួន ១៧នាក់ មាន: អាយុក្រោម១៥ឆ្នាំ ០៤នាក់ អាយុ១៥-១៧ឆ្នាំ ០៦នាក់ និងអាយុពី១៨ឆ្នាំឡើង ០៧នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច ១៣នាក់ និងប្រគល់ឲ្យគ្រួសារ ០៤នាក់) ក្នុងនោះមានចែកជា៖

១. ករណីអំពើជួញដូរមនុស្ស

បង្ក្រាបបាន ០៤ករណី លើ០៨ករណី (ថយចុះ ០៤ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ០៥នាក់(ស្រី)។

សង្គ្រោះជនរងគ្រោះចំនួន ០៩នាក់ មាន: អាយុ១៥-១៧ឆ្នាំ ០៣នាក់ និងអាយុពី១៨ឆ្នាំឡើង ០៦នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច ០៩នាក់)។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|
| -ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់ឆ្លងដែន | ០១ | ០៤ | ០២ | |
| -អំពើលក់ដូរមនុស្សសម្រាប់នាំឆ្លងដែន | ០៣ | ០៥ | ០៣ | |
| *សរុប* | *០៤ ករណី* | *០៩ នាក់* | *០៥ នាក់* | |

២. ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ

បង្ក្រាបបាន ០៥ករណី លើ០៩ករណី (ថយចុះ ០៤ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ០៧នាក់ (ស្រី ០១នាក់ ជនបរទេស ០១នាក់)។

សង្គ្រោះជនរងគ្រោះចំនួន ០៨នាក់ មានៈ អាយុក្រោម១៥ឆ្នាំ ០៤នាក់ អាយុ១៥-១៧ឆ្នាំ ០៣នាក់ និងអាយុពី១៨ឆ្នាំឡើង ០១នាក់ (ប្រគល់ទៅមន្ទីរសង្គមកិច្ច ០៤នាក់ និងប្រគល់ឲ្យគ្រួសារ ០៤នាក់)។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|
| -សញ្ចារកម្ម(ទាក់ទងនឹងពេស្យាចារកុមារ) | ០១ | ០៤ | ០៣ | |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៣ | ០៣ | ០៣ | |
| -អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០១ | ០១ | ០១ | អាមេរិក ០១ |
| *សរុប* | *០៥ ករណី* | *០៨ នាក់* | *០៧ នាក់* | *០១ នាក់* |

## ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

### ឃ.១. ការទទួល និងសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និងផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ

#### ឃ.១.១. ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់

- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

យោងស្ថិតិ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានបញ្ជូនពលរដ្ឋខ្មែរសង្ស័យរងគ្រោះដោយអំពើជួញដូរមនុស្ស តាមរយៈស្ថានទូត ស្ថានតំណាងនៅបរទេស និងបានសហការជាមួយអង្គការដៃគូ សរុបចំនួន ៣.១២៦នាក់(ស្រី ១.៤៣៨នាក់)ក្នុងនោះមានៈ

| ល.រ | ឈ្មោះប្រទេសគោលដៅ | មូលហេតុនៃការវិលត្រឡប់ | សរុប | ស្រី | ប្រុស |
|---|---|---|---|---|---|
| ១ | ម៉ាឡេស៊ី | ធ្វើការខុសច្បាប់ | ១៨ | ១១ | ០៧ |
| ២ | ចិន | សង្ស័យជួញដូរនិងចាញ់បោកមេខ្យល់ | ០៦ | ០៦ | ០ |
| ៣ | ថៃ | ពលករខុសច្បាប់ | ៣.១០២ | ១.៤២១ | ១.៦៨១ |
| សរុបរួម | | | ៣.១២៦នាក់ | ១.៤៣៨នាក់ | ១.៦៨៨នាក់ |

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ស.អ.យ)

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ក្រុមការងារការពារជនរងគ្រោះ) និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះដែលធ្វើមាតុភូមិនិវត្តន៍ ពីប្រទេសនានាសរុបចំនួន ០៦នាក់(ប្រុស) ក្នុងនោះមានៈ

- មជ្ឈមណ្ឌលសំចតប៉ោយប៉ែត បានទទួលកុមាររងគ្រោះដោយអំពើជួញដូរមនុស្ស ដែលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសថៃ ចំនួន ០៦នាក់(ប្រុស)។

- អគ្គស្នងការដ្ឋាននគរបាលជាតិ

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានទទួល និងសម្ភាសពលករខ្មែររងគ្រោះចំនួន ១៥នាក់(ស្រី) ដែលត្រឡប់ពីប្រទេសចិន ១២នាក់ និងប្រទេសម៉ាឡេស៊ី ០៣នាក់។ តាមការសម្ភាសបានរកឃើញមេខ្យល់ ០២នាក់ត្រូវបានបង្ក្រាប និងដឹងថាទៅតាមរយៈមេខ្យល់ ១២នាក់ និងទៅតាមរយៈក្រុមហ៊ុន ០១នាក់។

▪ អគ្គនាយកដ្ឋានអន្តោប្រវេសន៍

បានទទួលពលរដ្ឋខ្មែរ ដែលអាជ្ញាធរបរទេសបញ្ជូនត្រឡប់មកកម្ពុជាវិញ ចំនួន ៨៣លើក/១៣០លើក មនុស្សចំនួន ១.០០៤នាក់(ស្រី ៣០២នាក់ កុមារ ១១៩នាក់)។ ក្នុងនោះតាមៈ

- ច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ ១៩លើក មនុស្សចំនួន ៥០នាក់
- ច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ ៦៣លើក មនុស្សចំនួន ៩៥៣នាក់

ច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ឡាវ ០១លើក មនុស្សចំនួន ០១នាក់។

▪ **ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត**

**ស្នងការដ្ឋាននគរបាលខេត្ត** ចំនួន៣ បានទទួល និងសម្ភាសពលករខ្មែរ ដែលអាជ្ញាធរបរទេសចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ និងតាមច្រកព្រំដែនអន្តរជាតិបារិតសរុបចំនួន ៦៣លើក មនុស្សចំនួន ១.០២០នាក់(ស្រី ៣០១នាក់ អនីតិជន ១៥០នាក់) ក្នុងនោះមានៈ

- **ខេត្តបន្ទាយមានជ័យ** ចំនួន ៤៧លើក មនុស្សចំនួន ៨៧៧នាក់ (ស្រី ២៤៩នាក់) អនីតិជនចំនួន ១២៥នាក់។
- **ខេត្តបាត់ដំបង** ចំនួន ០៩លើក មនុស្សចំនួន ១០១នាក់ (ស្រី ៣១នាក់) អនីតិជនចំនួន ០៨នាក់។
- **ខេត្តកោះកុង** ចំនួន ០៦លើក មនុស្សចំនួន ១៦នាក់ (ស្រី ០៤នាក់)
- **ខេត្តស្វាយរៀង** ចំនួន ០១លើក មនុស្សចំនួន ២៦នាក់ (ស្រី ១៧នាក់) អនីតិជនចំនួន ១៧នាក់។

## ឃ.២. ការស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស

▪ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ស.អ.យ)

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ក្រុមការងារការពារជនរងគ្រោះ) និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលបានសេវាស្នាក់នៅ និងការស្តារនីតិសម្បទា ចំនួន ១៩នាក់(ស្ត្រី ០៥នាក់ កុមារ ០៧នាក់) រួមមានៈ

- មជ្ឈមណ្ឌលសំចតប៉ោយប៉ែត បានផ្តល់សេវាស្នាក់នៅរយៈពេលខ្លី និងស្តារនីតិសម្បទា ដល់ជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន ១៩នាក់(ស្ត្រី ០៥នាក់ កុមារ ០៧នាក់) មានករណីអំពើជួញដូរមនុស្ស ០៦នាក់ និងងាយរងគ្រោះ ១៣នាក់ រួចបានបញ្ជូនទៅទទួលសេវាបន្តនៅបន្តអង្គការគ្រួសារថ្មី អង្គការតំណក់ទឹក អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) ដើម្បីទទួលសេវាអប់រំក្នុង និងក្រៅប្រព័ន្ធ និងសេវាផ្សេងៗទៀតមុនពេលធ្វើសមាហរណកម្មត្រឡប់ទៅផ្ទះវិញ។

## ឃ.៣. ការធ្វើសមាហរណកម្មជនរងគ្រោះ និងខាយរងគ្រោះ

- បានធ្វើសមាហរណកម្មស្ត្រីរងគ្រោះដោយអំពើជួញដូរមនុស្ស ត្រឡប់ទៅសហគមន៍វិញចំនួន ០២នាក់ ករណីរៀបអាពាហ៍ពិពាហ៍ក្លែងក្លាយ ០១នាក់ និងទូកនេសាទ ០១នាក់។
- មន្ទីរសង្គមកិច្ចខេត្តស្វាយរៀង សហការជាមួយអង្គការដៃគូរ បានធ្វើសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្សត្រឡប់ទៅសហគមន៍វិញចំនួន ៣៧នាក់(ស្ត្រី ២០នាក់ កុមារ១៧នាក់) ជាករណីជួញដូរមនុស្ស ១០នាក់ អាជីវកម្មផ្លូវភេទ ១០នាក់ និងជួញដូរកម្លាំងពលកម្ម ១៧នាក់។

# III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល

## ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

### ក.១. ការងារបណ្តុះបណ្តាល

#### ក.១.១.ការបណ្តុះបណ្តាលក្នុងប្រទេស

តារាងវគ្គបណ្តុះបណ្តាល

| ល.រ | សកម្មភាព | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|---|
| ១ | នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន សហការជាមួយ អង្គការសង្គ្រោះដោតវាសនា បើកវគ្គបណ្តុះបណ្តាល ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ នៅភោជនីយដ្ឋាន ទន្លេបាសាក់២។ | ១ | ៣០ | ០៧ |
| ២ | ខេត្តត្បូងឃ្មុំ៖ ស្នងការដ្ឋាននគរបាលខេត្ត សហការជាមួយអង្គការសម្ព័ន្ធចាប់ដៃ បើកវគ្គបណ្តុះបណ្តាល ស្តីពីនីតិវិធីស៊ើបអង្កេត និងក្រមសីលធម៌របស់អ្នកសម្ភាសន៍ នៅស្នងការដ្ឋាននគរបាលខេត្តត្បូងឃ្មុំ។ | ០១ | ៣៥ | ០២ |
| ៣ | ខេត្តព្រៃវែង៖ បើកវគ្គបណ្តុះបណ្តាល ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដល់ក្រុង ស្រុក និងមន្ទីរ អង្គភាពជុំវិញខេត្ត។ | ០១ | ៣៩ | ២០ |
| ៤ | ខេត្តកោះកុង៖ មន្ទីរកិច្ចការនារីខេត្ត បើកវគ្គបណ្តុះបណ្តាល ស្តីពីអំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព សមាសភាពចូលរួមមាន អាជ្ញាធរមូលដ្ឋាន មន្ទីរពាក់ព័ន្ធ និងប្រជាពលរដ្ឋ។ | ០១ | ៣២ | ១៧ |
| ៥ | ខេត្តព្រះសីហនុ៖ លេខាធិការដ្ឋាន គ.ខ.ប.ជ បើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ | ០១ | ៤៣ | ១៧ |
| ៦ | ខេត្តកំពត៖ បើកវគ្គបណ្តុះបណ្តាល ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពដល់ប្រជាពលរដ្ឋ នៅឃុំត្រពាំងបី ស្រុកឈូក និងឃុំដំណាក់កន្ទួតខាងត្បូង ស្រុកកំពង់ត្រាច។ | ០២ | ៦០ | ២៣ |
| ៧ | ខេត្តសៀមរាប៖<br>-មន្ទីរធម្មការ និងសាសនាខេត្ត បើកវគ្គបណ្តុះបណ្តាល ស្តីពីគ្រឿងញៀន អំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចពលកម្មកុមារ។<br>-ស្នងការដ្ឋាននគរបាលខេត្ត សហការជាមួយអង្គការ APLE បើកវគ្គបណ្តុះបណ្តាល ស្តីពីការអនុវត្តបែបកុមារមេត្រី ដើម្បីការពារជនរងគ្រោះ និងកុមារសាក្សី ក្នុងនីតិវិធីស៊ើបអង្កេតបទល្មើសកេងប្រវ័ញ្ចផ្លូវភេទ ដល់អធិការដ្ឋាន ប៉ុស្តិ៍នគរបាល និងមន្ត្រីពាក់ព័ន្ធ។ | ០២ | ១២៨ | ០៧ |
| | សរុប | ០៩ វគ្គ | ៣៦៧ នាក់ | ៩៣ នាក់ |

**ក.២. សិក្ខាសាលា**

ក.២.១.សិក្ខាសាលាក្នុងប្រទេស

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)

សហការជាមួយអង្គការ APLE រៀបចំសិក្ខាសាលា ស្តីពីកិច្ចបង្ការ និងការឆ្លើយតបនឹងបទល្មើសផ្លូវភេទលើកុមារ ក្នុងវិស័យទេសចរណ៍ ដែលមានការចូលរួមពីក្រុមការងារអន្តរក្រសួង ស្ថាប័នទាំង៦ គ.រ.ប.ជ/គ.ខ.ប.ជ និងអង្គការដៃគូ នៅទីស្តីការក្រសួងមហាផ្ទៃ មានសិក្ខាកាមចូលរួមចំនួន **៧៧**នាក់ (ស្រី ២៩នាក់)។

- ខេត្តសៀមរាប

មន្ទីរអប់រំ យុវជន និងកីឡាខេត្ត សហការជាមួយអង្គការ APLE បានរៀបចំសិក្ខាសាលា ស្តីពីយុទ្ធនាការសុវត្ថិភាពអ៊ីនធឺណិត ដល់ក្រុមយុវជន នៅមជ្ឈមណ្ឌលជាតិយុវជន ខេត្តសៀមរាប មានសិក្ខាកាមចូលរួមចំនួន ៦០នាក់។

## ខ. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ខ.១ សន្និសីទថ្នាក់ជាតិ និងអន្តរជាតិ

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)

បានរៀបចំនូវសន្និសីទអន្តរជាតិ ស្តីពីទេសន្តរប្រវេសន៍ និងការជួញដូរមនុស្សនៅអាស៊ី ពីការប្រឈមការការពារ ការយល់ដឹង និងភាពជាដៃគូ ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ អញ្ជើញចូលរួមក្នុងអង្គសន្និសីទមាន អង្គការជីវិតថ្លៃថ្នូរកម្ពុជា អង្គការដៃគូ អនុវត្តការងារពាក់ព័ន្ធនឹងទេសន្តរប្រវេសន៍ចំនួន ១៤ប្រទេស តំណាងពីអង្គការយូអិនវូមែន តំណាងពីភ្នាក់ងារប្រចាំអាស៊ី និងប៉ាស៊ីហ្វិច(EICA) តំណាងពីអង្គការវីនរ៉ក់កម្ពុជា តំណាងពីការិយាល័យ សហគមន៍អង្គការឡូទៃរៃនពិភពលោក និងពីអង្គការដៃគូមួយចំនួនក្នុងប្រទេសកម្ពុជា នៅសណ្ឋាគារអឺរ៉ាភ្នំពេញ។

### ខ.២ កិច្ចប្រជុំ ជាអន្តរជាតិនៅក្នុងប្រទេស និងក្រៅប្រទេស

➢ **កិច្ចប្រជុំក្នុងប្រទេសជាលក្ខណៈអន្តរជាតិ**

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ស.អ.យ)

បានរៀបចំកិច្ចប្រជុំពិភាក្សាជាមួយភាគីថៃ ស្តីពីដំណើរការសាងសង់មជ្ឈមណ្ឌលសំចត និងស្តារនីតិសម្បទាប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដឹកនាំដោយឯកឧត្តម **ញ៉ឹក វណ្ណារ៉ា** រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងភាគីថៃ ដឹកនាំដោយលោកជំទាវ **SASITORN WONGWEERACHOTKIT** អគ្គនាយករងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ នៅទីស្តីការក្រសួង ស.អ.យ មានអ្នកចូលរួមចំនួន ៣៥នាក់(ស្រី ១២នាក់)។

➢ **កិច្ចប្រជុំក្នុងប្រទេស**

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ)

- លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញដឹកនាំៈ

កិច្ចប្រជុំពិភាក្សាអន្តរក្រសួងៈ

- ស្តីពីការប្រតិបត្តិនីតិវិធីតាមស្តង់ដាជាមួយអន្តរក្រសួង ស្ថាប័ន អ្នកចូលរួមចំនួន **២៧**នាក់ (ស្រី ០៥នាក់)។

- ស្តីពីសេចក្តីព្រាងនីតិវិធីតាមស្តង់ដាប្រតិបត្តិ កិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ រវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលព្រះរាជាណាចក្រថៃ លើកទី៤ ចំនួន ០៣លើក អ្នកចូលរួមចំនួន ៧៥នាក់ (ស្រី ១២នាក់)។

កិច្ចប្រជុំផ្ទៃក្នុង៖

- ស្តីពីការពិគ្រោះយោបល់ចំវេទិកាជាតិអន្តរសាសនា លើកទី៣ ឆ្នាំ២០១៩ អ្នកចូលរួមចំនួន ២១នាក់។
- ពិភាក្សាដៃគូអភិវឌ្ឍន៍ ក្នុងកិច្ចសហប្រតិបត្តិ ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ស្តីពីការរៀបចំកិច្ចប្រជុំកម្រិតបច្ចេកទេសពហុប្រទេសបញ្ចូន (កម្ពុជា ឡាវ មីយ៉ាមា) អ្នកចូលរួមចំនួន ២៥នាក់ (ស្រី ០៩នាក់)។

## ខ.៣. ការទទួលជួបពិភាក្សាការងារ

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)

លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអនុញ្ញាតិទទួលជួបពិភាក្សាការងារជាមួយ៖

- ប្រតិភូជាប្រធាន និងតំណាងអង្គការការីតាស ប្រចាំប្រទេសក្នុងតំបន់ (ថៃ ប៉ាគីស្ថាន ជប៉ុន) នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។

## ខ.៤. ការងារសម្របសម្រួល

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសគឺ ៣០លើក មានអ្នកចូលរួមសរុប ៩០៦នាក់ (ស្រី ២៦១នាក់) ក្នុងនោះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ០៨លើក ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ០២លើក និងលេខាធិការដ្ឋានរាជធានី-ខេត្ត ចំនួន ២០លើក។ (ឧបសម្ព័ន្ធ១)

# III. ការសន្និដ្ឋានវាយតម្លៃ

## ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែងរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឲ្យកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍ ០៤ចំណុច និងវិធានការ ០៦ចំណុច របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- យើងមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។

- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួង ស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

## ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម និងសេសសល់មួយចំនួនដូចជា៖

- ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នាជាប្រព័ន្ធ និងបែងចែកការទទួលខុសត្រូវបន្តរហូតចប់ការងារ។
- ការផ្ញើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឲ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។

## គ. សំណូមពរ

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការដៃគូត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្ដល់របាយការណ៍ឲ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ របស់ក្រុមការងារអន្តរជំនាញ តាមវិស័យនីមួយៗ ដើម្បីប្រសិទ្ធភាពការងារ។
- ស្នើឲ្យលេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ផ្ដល់របាយការណ៍ឲ្យបានទៀងទាត់ ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ។
- បើកវគ្គបណ្ដុះបណ្ដាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឲ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ស្នើសុំក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្ដីសម្រេច ស្ដីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច។

## ឃ. សន្និដ្ឋាន

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្ដេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។

- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅ ការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឲ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តិនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋ ដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើនពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## IV. ទិសដៅខែសីហា ឆ្នាំ ២០១៩

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឲ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួម ដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាព ជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដកហូតសរីរាង្គជួញដូរ ការរត់ពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។

៣. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៤. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៥. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឲ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៦. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៧. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្ស ដែល សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។

៨. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឲ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឲ្យបានត្រឹមត្រូវ។

៩. បន្តរៀបចំវិធានការ "គ្រប់គ្រងលំហូរ ពលករទេសន្តប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី" (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ )។

១០. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

១១. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។

១២. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្ន មុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃ........................ខែ.............ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី.......ខែ..........ឆ្នាំ២០១៩

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ_ប៊ុនអេង**

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"

- ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន
- សមាជិកក្រុមការងារគ.ជ.ប.ជ
- អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

"ដើម្បីជូនជ្រាប"

- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី១

## តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន ៣០លើក) មនុស្សចំនួន ៩០៦នាក់ (ស្រី ២៦១នាក់)

| ស្ថាប័ន សម្របសម្រួល | សកម្មភាព |
| --- | --- |
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) | សម្របសម្រួលចំនួន ០៨លើក អ្នកចូលរួមចំនួន ១៣០នាក់<br>▪ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញជាអធិបតីភាពក្នុងកិច្ចប្រជុំ ស្តីពី"យុត្តិធម៌ព្រហ្មទណ្ឌ" នៅសាលប្រជុំសាលាខេត្តសៀមរាប មានការចូលរួមពីតំណាងស្ថាប័ន តុលាការ មន្ទីរអង្គភាព ពាក់ព័ន្ធជុំវិញខេត្ត និងតំណាងអង្គការដៃគូអន្តរជាតិ។<br>▪ លោកជំទាវ ឧត្តមសេនីយ៍ឯក ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញចូលរួមប្រជុំ និងដឹកនាំកិច្ចប្រជុំ៖<br>○ ស្តីពីវឌ្ឍនៈភាពការងារក្របខណ្ឌមន្ត្រីរាជការស៊ីវិល មន្ត្រីនគរបាលជាតិ នៅទីស្តីការក្រសួងមហាផ្ទៃ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។<br>○ ទ្វេភាគីរវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ ស្តីពីការកសាងមជ្ឈមណ្ឌលសំចត ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងក្រុមជនងាយរងគ្រោះ នៅប៉ោយប៉ែត ក្រោមអធិបតីភាពក្រោមអធិបតីភាព ឯកឧត្តម ញឹក វណ្ណារ៉ា រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុជន និងយុវនីតិសម្បទា នៅទីស្តីការក្រសួងសង្គមកិច្ច។<br>○ ស្វែងយល់ពីការធ្វើបទបង្ហាញ ស្តីពី App ពី Partner Resources សម្រាប់ថ្នាក់ដឹកនាំ និងមន្ត្រី នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>▪ **លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**<br>- លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ ២២ច្បាប់ លិខិតចូល ២៤ច្បាប់។<br>- លិខិតរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ ០៩ច្បាប់ លិខិតចូល ១៤ច្បាប់។<br>- រៀបចំកិច្ចប្រជុំ និងធ្វើកំណត់ហេតុ រាល់ពេលប្រជុំ។<br>- បូកសរុបរបាយការណ៍ប្រចាំសប្តាហ៍ និងខែកក្កដា ឆ្នាំ២០១៩ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- បូកសរុបរបាយការណ៍ខែកក្កដា ឆ្នាំ២០១៩ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ |

- ប្រមូលរបាយការណ៍ពីអន្តរក្រសួង ស្ថាប័ន និងរាជធានី/ខេត្តទាំង២៥។
- រៀបចំ និងបញ្ជូនលិខិតអញ្ជើញចូលរួមកិច្ចប្រជុំ ទៅកាន់ក្រសួង ស្ថាប័ន អង្គភាព រាជធានី-ខេត្ត និងអង្គការដៃគូពាក់ព័ន្ធនានា។
- ចងក្រងព័ត៌មាន រូបភាព និងសកម្មភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចូលក្នុងបណ្ណាសារវីគី។
- ស្រាវជ្រាវព័ត៌មានពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សពីមជ្ឈដ្ឋានផ្សេងៗ ជាពិសេសព័ត៌មានដែលចុះផ្សាយ នៅក្នុងបណ្តាញសង្គម និងគេហទំព័រនានា។
- Scan & Uploaded ឯកសារចូលក្នុងបណ្ណាសារនៃប្រព័ន្ធ wiki បានចំនួន ១៣ច្បាប់។
- អាប់ឡូតរូបភាពសកម្មភាព គ.ខ.ប.ជ ចូលបណ្ណាល័យរូបភាពក្នុងប្រព័ន្ធអ៊ិនធើណេត wiki បានចំនួន ៣១សកម្មភាព។

▪ **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់៖**

- លោកប្រធានក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ បានដឹកនាំក្រុមការងារចូលរួមធ្វើបទឧទ្ទេសនាមក្នុងកម្មវិធីសិក្ខាសាលា ស្តីពីការពង្រឹងសមត្ថភាពក្រមសីលធម៌ និងការងារទប់ស្កាត់អំពើជួញដូរមនុស្ស ជូនដល់អ្នកសារព័ត៌មាន ពិធីករ និងពិធីការិនី វិទ្យុ និងទូរទស្សន៍ ក្រោមអធិបតីភាព ឯកឧត្តម ជុំ កុសល រដ្ឋលេខាធិការក្រសួងព័ត៌មាន និងបិទបញ្ចប់កម្មវិធីដោយ ឯកឧត្តម ហ៊ុយ សារ៉ាវុធ រដ្ឋលេខាធិការក្រសួងព័ត៌មាន និងជាតំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម រដ្ឋមន្ត្រីក្រសួងព័ត៌មាន នៅសាកលវិទ្យាល័យអន្តរជាតិ IU។
- លោកប្រធាន អនុប្រធាន និងមន្ត្រី ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានចូលរួមក្នុងវគ្គបណ្តុះបណ្តាល ស្តីពីការថែទាំដោយមានការយល់ដឹងអំពីការប៉ះទង្គិចផ្លូវចិត្ត តបតាមការស្នើសុំរបស់អង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM)កម្ពុជា នៅភោជនីយដ្ឋានទន្លេបាសាក់២។

▪ **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ៖**

- លោកប្រធានក្រុមការងារទំនាក់ទំនងអន្តរជាតិ បានអញ្ជើញចូលរួមធ្វើបទបង្ហាញមួយ ស្តីពីគម្រោងគ្រប់គ្រងទិន្នន័យនៃការផ្តល់សេវា និងការបញ្ជូន នៅក្នុងវគ្គសិក្ខាសាលាសេវាសង្គមកិច្ចផ្ទាល់នៅកម្ពុជា សិក្ខាសាលានេះមានការអញ្ជើញចូលរួមចំនួន ១៣០នាក់ មកពីក្រសួង មន្ទីរពាក់ព័ន្ធ អង្គការជាតិ អង្គការអន្តរជាតិ និងគ្រឹះស្ថានអប់រំ ដែលប្រព្រឹត្តិទៅនៅមជ្ឈមណ្ឌល អាយ ស៊ី អែហ្វ។
- លោកស្រីអនុប្រធានក្រុម បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពី "ការថែទាំដោយមានការយល់ដឹងអំពីការប៉ះទង្គិចផ្លូវចិត្ត" រៀបចំដោយអង្គការអន្តរជាតិទេសន្តរប្រវេសន៍ )IOM) កម្ពុជា ដែលប្រព្រឹត្តិទៅនៅភោជនីយដ្ឋាន ទន្លេបាសាក់២។

| | |
|---|---|
| **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** | - បានរៀបចំកិច្ចប្រជុំគណៈកម្មាការចំពោះកិច្ចដើម្បីសម្របសម្រួល ដំណើរការសាងសង់មជ្ឈមណ្ឌលសំចត និងស្ថានីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីត្រៀមរៀបចំកិច្ចប្រជុំទ្វេភាគីជាមួយភាគីថៃ អ្នកចូលរួមចំនួន១៨នាក់ (ស្រី០៥នាក់)។<br>- បានចាត់មន្ត្រីចូលរួមជាគ្រូឧទ្ទេសក្នុងវគ្គបណ្តុះបណ្តាល ស្តីពីការសង្គ្រោះចិត្តសាស្ត្របឋម និងសមាហរណកម្ម ជាមួយអង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) នៅខេត្តសៀមរាប អ្នកចូលរួមចំនួន៩៧នាក់(ស្រី៤២នាក់)។ |
| **លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន ២០លើក អ្នកចូលរួមសរុបចំនួន ៦៦១នាក់ (ស្រី ២១៤នាក់)** | |
| **ខេត្តកណ្តាល** | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រចាំខែសីហា ឆ្នាំ២០១៩ អ្នកចូលរួមចំនួន៣០នាក់ (ស្រី១៧នាក់)។<br>- ក្រុមការងារក្រុង-ស្រុក បានប្រជុំប្រចាំខែសីហា ចំនួន១២លើក អ្នកចូលរួមចំនួន២៦៧នាក់ (ស្រី១៦២នាក់)។ |
| **ខេត្តកំពង់ឆ្នាំង** | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានប្រជុំប្រចាំខែសីហា ចំនួន០១លើក។ |
| **ខេត្តកោះកុង** | - បានប្រជុំពិភាក្សាស្តីពី ការរៀបចំទីកន្លែងសម្រាប់ពលករដែលភាគីថៃបញ្ជូនមក ដើម្បីស្នាក់នៅបណ្តោះអាសន្ន អ្នកចូលរួមចំនួន១៥នាក់ (ស្រី០៣នាក់)។ |
| **ខេត្តប៉ៃលិន** | - ឯកឧត្តម **ផាន់ ចាន់ថុល** ប្រធានគណៈកម្មាធិការ គ.ខ.ប.ជ ខេត្ត បានដឹកនាំកិច្ចប្រជុំប្រកាសតែងតាំងសមាសភាព គ.ខ.ប.ជ និងក្រុមជំនាញអន្តរមន្ទីរ អង្គភាព មានអ្នកចូលរួម៤៩នាក់(ស្រី០៦នាក់)។ |
| **ខេត្តសៀមរាប** | - លេខាធិការដ្ឋាន គ.ខ.ប.ជ សហការជាមួយស្ថាប័នតុលាការ រៀបចំកិច្ចប្រជុំពង្រឹងសមត្ថភាពស្តីពី យុត្តិធម៌ព្រហ្មទណ្ឌ នៅរដ្ឋបាលសាលាខេត្ត មានអ្នកចូលរួម ២០០នាក់។<br>- រដ្ឋបាលស្រុកក្រឡាញ់ បានប្រជុំណែនាំដល់ឃុំទាំង១០ ឲ្យដាក់បញ្ចូលសកម្មភាព ស្តីពីការបង្ក្រាប ការទប់ស្កាត់ ការណែនាំ ស្តីពីអំពើជួញដូរមនុស្ស ចូលទៅក្នុងផែនការវិនិយោគឃុំ ចំនួន ០១លើក។ |
| **ខេត្តស្ទឹងត្រែង** | - មន្ទីរកិច្ចការនារីខេត្ត បានចុះពង្រឹងសមត្ថភាពដល់ គ.ក.ន.ក ចំនួន០២លើក ក្នុងស្រុកបូរីអូរស្វាយសែនជ័យ និងស្រុកថាឡាបរិវ៉ាត់ ស្តីពីការរំលោភបំពាន និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព អ្នកចូលរួមចំនួន៥៤នាក់ (ស្រី២០នាក់)។ |
| **ខេត្តស្វាយរៀង** | - អង្គការចាលហ្វាន់កម្ពុជា និងអង្គការ CCPCR រៀបចំកិច្ចប្រជុំឆ្លុះបញ្ចាំងពីបញ្ហាអំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុក ដើម្បីស្វែងយល់ពីស្ថានភាព និងបញ្ហាប្រឈមពាក់ព័ន្ធ អ្នកចូលរួមចំនួន៤៦នាក់ (ស្រី០៦នាក់)។ |